ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

ថ្ងៃព្រហស្បតិ៍ ២កើត ខែ ពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ ២០១៨

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីបញ្ហាស្លាកសញ្ញាលើបាវអង្ករ ដែលបានដាក់លក់លើទីផ្សារបរទេស

(ភ្នំពេញ)៖ ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណៈជន មេត្តាជ្រាបថា កាលពីថ្មីៗនេះក្រសួងពាណិជ្ជកម្មបានទទួលព័ត៌មាន ទាក់ទិននឹងការក្លែងបន្លំអត្តសញ្ញាណរបស់ទំនិញអង្ករបរទេស (ថៃឡង់ដ៏) ដែលមានដាក់រូបប្រាសាទអង្គរវត្ត និងឈ្មោះជាខេមរៈភាសាថា «អង្ករក្រអូបពិសេស» ដើម្បីបំភាន់អ្នកប្រើប្រាស់ពីប្រភពដើមនៃទំនិញ។

បើតាមការស្រាវជ្រាវបឋមរបស់ក្រសួងបានឲ្យដឹងថា ទំនិញអង្ករខាងលើ មានដាក់លក់នៅក្នុងទីក្រុងម៉ុងរ៉េអាល់នៃប្រទេសកាណាដា តែប៉ុណ្ណោះ គឺពុំមានដាក់លក់នៅតាមទីផ្សារនៃប្រទេសផ្សេងៗឡើយ។

ក្នុងន័យនេះ ក្រសួងពាណិជ្ជកម្មសូមបញ្ជាក់ថា ការនាំចេញអង្ករពីកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ជាពិសេសទីផ្សារសហគមន៍អឺរ៉ុប សហរដ្ឋអាមេរិក និងកាណាដា គឺត្រូវបានឆ្លងកាត់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល (ចាប់តាំងពីដំណាក់កាលផលិត រហូតដល់មាត់ច្រកនាំចេញ) ដោយមានការចូលរួមសហការពីវិស័យឯកជន និងក្រុមហ៊ុននាំចេញ ជាដើម។

ឆ្លើយតបបាតុភាពខាងលើ ក្រសួងពាណិជ្ជកម្ម នឹងធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីចាត់វិធានការតាមមធ្យោបាយការទូត និងផ្លូវច្បាប់នានា ដើម្បីស្វែងរកប្រភព និងបុគ្គលល្មើស សំដៅបញ្ឈប់ការធ្វើចរាចរណ៍ទំនិញក្លែងបន្លំអត្តសញ្ញាណនេះ។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469